**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១៣២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងស្រុកកំពង់លាវ និងស្រុកពារាំង ខេត្តព្រៃវែង

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

Pheakdey Law Book Store

www.pheakdeylaw.com

## សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងស្រុកកំពង់លាវ និងស្រុកពារាំង ខេត្តព្រៃវែង ដោយកាត់យកឃុំចំនួន ០២ នៃស្រុកពារាំងគឺ ឃុំព្រែកតាសរ និងឃុំកំពង់ឫស្សី មកបញ្ចូលក្នុងស្រុកកំពង់លាវ ។

ផ្អែកតាមការកែសម្រួលនេះ ព្រំប្រទល់រដ្ឋបាលរវាងស្រុកកំពង់លាវ និងស្រុកពារាំង ខេត្តព្រៃវែង ត្រូវបានកំណត់ ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានផ្លាស់ប្តូរទីតាំងសាលាស្រុកកំពង់លាវដែលស្ថិតនៅក្នុងឃុំតាកោ មកនៅទីតាំងថ្មីស្ថិតនៅក្នុងឃុំពោធិ៍រៀង ។

**មាត្រា ៣.-**

ត្រូវបានប្តូរឈ្មោះស្រុកកំពង់លាវ ខេត្តព្រៃវែង មកជាស្រុកពោធិ៍រៀង ខេត្តព្រៃវែង ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្តព្រៃវែង គណៈអភិបាលខេត្តព្រៃវែង ក្រុមប្រឹក្សាស្រុក ពោធិ៍រៀង គណៈអភិបាលស្រុកពោធិ៍រៀង ក្រុមប្រឹក្សាស្រុកពារាំង គណៈអភិបាលស្រុកពារាំង ក្រុមប្រឹក្សាឃុំពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

PheakdeyLaw Book Store

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី
ខេត្តព្រៃវែង

## ផែនទីកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងស្រុកពោធិ៍រៀង និង ស្រុកពារាំង ខេត្តព្រៃវែង

មាត្រដ្ឋាន: 1:90,000



| OBJECTID | SHAPE* | X_Proj | Y_Proj |
|---|---|---|---|
| 1 | Point | 513105 | 1277692 |
| 2 | Point | 514196 | 1280544 |
| 3 | Point | 519812 | 1280341 |
| 4 | Point | 520074 | 1277804 |
| 5 | Point | 521153 | 1276313 |
| 6 | Point | 521926 | 1275048 |
| 7 | Point | 521119 | 1274425 |
| 8 | Point | 521429 | 1273795 |
| 9 | Point | 521387 | 1273604 |
| 10 | Point | 520536 | 1272470 |
| 11 | Point | 520356 | 1273535 |
| 12 | Point | 519148 | 1273424 |
| 13 | Point | 517308 | 1274785 |
| 14 | Point | 515851 | 1274335 |
| 15 | Point | 514904 | 1274465 |
| 16 | Point | 514856 | 1274752 |
| 17 | Point | 514008 | 1276175 |
| 18 | Point | 514185 | 1276035 |
| 19 | Point | 514181 | 1276461 |
| 20 | Point | 514852 | 1276547 |
| 21 | Point | 514165 | 1277136 |
| 22 | Point | 513540 | 1277047 |
| 23 | Point | 522948 | 1274859 |
| 24 | Point | 522439 | 1275250 |
| 25 | Point | 523886 | 1275085 |
| 26 | Point | 524581 | 1275610 |
| 27 | Point | 524962 | 1275701 |
| 28 | Point | 526436 | 1275971 |
| 29 | Point | 526476 | 1276192 |
| 30 | Point | 524382 | 1276667 |
| 31 | Point | 524882 | 1277056 |
| 32 | Point | 524946 | 1277579 |
| 33 | Point | 524612 | 1279277 |
| 34 | Point | 525723 | 1279851 |
| 35 | Point | 528060 | 1280431 |
| 36 | Point | 527579 | 1281151 |
| 37 | Point | 527262 | 1283506 |
| 38 | Point | 526847 | 1284025 |
| 39 | Point | 523030 | 1282105 |
| 40 | Point | 522349 | 1283900 |
| 41 | Point | 521844 | 1284047 |
| 42 | Point | 519832 | 1282230 |

ព្រៃវែងថ្ងៃទី២៧ ខែមករា ឆ្នាំ ២០១១
គូរដោយ

បានពិនិត្យត្រឹមត្រូវ

បានពិនិត្យត្រឹមត្រូវ

បានពិនិត្យត្រឹមត្រូវ

បានឃើញ និង ពិនិត្យត្រឹមត្រូវ

បានពិនិត្យត្រឹមត្រូវ

បានពិនិត្យត្រឹមត្រូវ

បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី......ខែ......ឆ្នាំ ២០១១

បានឃើញ និង ឯកភាព
ព្រៃវែង ថ្ងៃទី......ខែ......ឆ្នាំ ២០១១

បានឃើញ និង ពិនិត្យត្រឹមត្រូវ
ព្រៃវែង ថ្ងៃទី......ខែ......ឆ្នាំ ២០១១

បានឃើញ និង ពិនិត្យត្រឹមត្រូវ
ថ្ងៃទី......ខែ......ឆ្នាំ ២០១១

www.pheakdeylaw.com